**BMI0180**

# សម្ភាសន៍ជាមួយឈ្មោះប៉ាន់ ធី ភេទប្រុស អាយុ៥៦ឆ្នាំ

## មុខងារជំនាន់ខ្មែរក្រហម "ប្រធានកងកុមារ និងចល័ត"

ស្រុកកំណើតនៅភូមិកំពង់ថ្កូវ ឃុំទឹកជោរ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

រស់នៅភូមិដូនប្រែង ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១១

សម្ភាសន៍ដោយៈ ឆាយ ឈុនលី

០១:០៦:០៩

៣៥ទំព័រ

ឈុនលី : ចឹងអ៊ំ ជំរាបសួរខ្ញុំសុំណែនាំបន្តិចសិនខ្ញុំឈ្មោះ ឈុនលី មកពីខាងមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយ' មកដើម្បីសួរអំពីប្រវត្តិរបស់អ៊ំឆ្លងកាត់សម័យខ្មែរក្រហមយ៉ាងម៉េច ការងារអ៊ំធ្វើនៅត្រពាំងថ្មហ្នឹងយ៉ាងម៉េចដើម្បីឲ្យក្មេងជំនាន់ក្រោយបានរៀនបានសូត្រ ហើយខ្ញុំសុំថតរូបអ៊ំដែរអត់អីឯណាហ្អឺអ៊ំ?

ធី : បាទ!មានទៅអី ។

ឈុនលី : ចាស!ហើយខ្ញុំយកអត្ថបទដែលខ្ញុំសំភាសន៍ជាមួយអ៊ំយកទៅសរសេរ ។

ធី : បាទ!

ឈុនលី : ចាស!អ៊ីចឹងខ្ញុំសុំចាប់ផ្ដើម ថ្ងៃនេះទី១៨ មិថុនា ។ ជំរាបខ្ញុំសុំស្គាល់ឈ្មោះអ៊ំ អ៊ំឈ្មោះអី?

ធី : នាមត្រកូលហ្អី?

ឈុនលី : ចាស!

ធី : ឈ្មោះ ប៉ាន់ ធី ។

ឈុនលី : ប៉ាន់ ធី ។

ធី : បាទ!

ឈុនលី : អាយុប៉ុន្មានហើយអ៊ំ?

ធី : អាយុ៥៦ ។

ឈុនលី : អាយុ៥៦ ភេទប្រុស ។ ស្រុកកំណើតនៅឯណាអ៊ំ?

ធី : នៅឃុំទឹកជោរ ស្រុកព្រះនេត្រព្រះ ។

ឈុនលី ៖ កើតនៅភូមិអីគេ?

ធី ៖ កំពង់ថ្កូវ ។

ឈុនលី ៖ កំពង់ថ្កូវ ឃុំ?

ធី ៖ ទឹកជោរ ។

ឈុនលី ៖ ព្រះនេត្រព្រះ?

ធី ៖ បាទ!

ឈុនលី ៖ ចុះរាល់ថ្ងៃរស់នៅភូមិ?

ធី ៖ ដូនប្រែង ។

ឈុនលី ៖ ដូនប្រែង ឃុំ?

ធី ៖ ព្រះនេត្រព្រះ ។

ឈុនលី ៖ ព្រះនេត្រព្រះដែរ ធំណាស់អីចឹង?

ធី ៖ ធំ ។

ឈុនលី ៖ ស្រុកហ្នឹងធំជាងគេប៉ុយ៉ាងម៉េច?

ធី ៖ តែ មិនជាធំទេ វែងអន្លាយណាសនាង តាំងពីដើមមកស្រុកព្រះនេត្រព្រះធំជាងគេ ។

ឈុនលី ៖ ម៉ាក្នុងខេត្តបន្ទាយមានជ័យហ្នឹង?

ធី ៖ បាទ! ស្រុកផង ឃុំផង ។

ឈុនលី ៖ ចុះអ៊ំកាលមុនសម័យខ្មែរក្រហមបានរៀនបានសូត្រទេ?

ធី ៖ ខ្ញុំរៀនបានដល់ត្រឹមថ្នាក់ទី១០ ទី១០ពីសង្គមមិញ១១ ១២ ។

ឈុនលី ៖ ចាស! បានដប់ប៉ុន្មាន?

ធី ៖ ត្រូវហើយបានថ្នាក់ទី១០ ។

ឈុនលី ៖ ទី១០ស្មើថ្នាក់ទី២ ។

ធី ៖ បាទ! ស្មើថ្នាក់ទី២យើងសព្វថ្ងៃ ទី៣ ។

ឈុនលី ៖ ចាស! ឪពុកម្ដាយអ៊ំឈ្មោះអី?

ធី ៖ តែ ឪពុកខ្ញុំឈ្មោះប៉ាន់ ថ្មី ។,

ឈុនលី ៖ ប៉ាន់ ថ្មី គាត់ឈ្មោះថ្មី?

ធី ៖ បាទ!

ឈុនលី ៖ ម្ដាយ' ?

ធី : លៀម ញ៉ក់ ។

ឈុនលី : លៀម ញ៉ក់ ចុះប្រពន្ធបស់អ៊ំឈ្មោះអី?

ធី : ភ្លឹម គង់ ។

ឈុនលី : ភ្លឹម?

ធី : ភ្លឹម ភ ដើផលស្រះអ៊ឹុនិផម ។

ឈុនលី : ភ្លឹម...

ធី : គង់ ។

ឈុនលី : ភ្លឹម គង់ ។

ធី : បាទ!

ឈុនលី : គាត់អាយុប៉ុន្មានហើយ?

ធី : អាយុ៥៧ ។

ឈុនលី : បងអ៊ំម៉ាឆ្នាំចឹង?

ធី : បាទ!

ឈុនលី : អ៊ំមានកូនប៉ុន្មាន?

ធី : កូនបួននាង!

ឈុនលី : ស្រីប៉ុន្មានប្រុសប៉ុន្មាន?

ធី : ស្រីបីប្រុសមួយ ។

ឈុនលី : ចុះអ៊ំកាលជំនាន់ លន់ នល់ អ៊ំធ្វើអីគេ?

ធី : អត់បានធ្វើអីទេ កម្មករ ។

ឈុនលី : កម្មករអីគេ?

ធី : កាលនោះដួបដែរតែខ្ញុំទៅនៅទន្លេ គេចទៅនៅទន្លេ ។

ឈុនលី : ជំនាន់ លន់ នល់ណាស?

ធី : ហ្នឹងហើយជំនាន់ លន់ នល់ ត្រូវទាហ៊ានតែគេចទៅនៅទន្លេសាប ។

ឈុនលី : គេចទាហាន?

ធី : បាទ!

ឈុនលី : គេចាប់ទាហានឆ្នាំណា?

ធី : ចាប់កាលនោះឆ្នាំ ភ្លេចហើយ ឆ្នាំ៦៨ ។

ឈុនលី ៖ មុន៧០ទៀត?

ធី ៖ បាទ!មុន ។

ឈុនលី ៖ ជំនាន់សម្តេចហើយហ្នឹង?

ធី ៖ ក្បែរហ្នឹងសម្តេចដែរ សម័យ៦៩ ។

ឈុនលី ៖ ៦៩?

ធី ៖ បាទ!ខ្ញុំពេញវ័យ ។

ឈុនលី ៖ គេចទៅនៅទន្លេ?

ធី ៖ បាទ!

ឈុនលី ៖ គេចទៅនៅទន្លេហ្នឹងនៅឯណាទៅ?

ធី ៖ នៅភ្នំក្រោម សៀមរាប ។

ឈុនលី ៖ ហួស!ទៅនៅសៀមរាប? ។

ធី ៖ បាទ!

ឈុនលី ៖ ទៅនៅជាមួយអ្នកណាទៅ?

ធី ៖ ទៅនៅជាមួយចៅកែ ។

ឈុនលី ៖ ធ្វើរបៀបស៊ីឈ្នួលចឹង?

ធី ៖ បាទ ។

ឈុនលី ៖ គេរកត្រី?

ធី ៖ រកត្រី ពីសង្គមចាស់ ។

ឈុនលី ៖ ហើយទៅចេះគេចរួចដែរទៅរកត្រី ។

ធី ៖ គេចផុតដល់មកជួបៗនៅសម័យ ប៉ុល ពត ។

ឈុនលី ៖ អីចឹងចុះអាខ្ទង់៧០ ៧១ ៧២ ៧៣ពេលគេទំលាក់សម្តេចហ្នឹងអ៊ំនៅឯណា?

ធី ៖ នៅសៀមរាប ត្រូវហើយ៧១ ខ្ញុំគេចទៅពី៧១ ។

ឈុនលី ៖ ៧១ទេមិនមែន៦៩ទេ?

ធី ៖ បាទ!៧១មិនមែន៦៩ទេ ។

ឈុនលី ៖ ចុះអាជិតចូលដល់៧៥ហ្នឹងនៅសៀមរាបមានជ្រួលច្របល់ទេ?

ធី ៖ នៅទន្លេសាប កាលនោះខ្ញុំនៅទន្លេសាប ខ្មែរក្រហមចាប់ផ្តើមសកម្មភាពបណ្តើរៗ ។

ឈុនលី ៖ មុន៧៥ហ្នឹង?

ធី ៖ បាទ!

ឈុនលី ៖ ខ្ទង់ចិតប៉ុន្មានអ៊ឹ?

ធី ៖ ៧៤ ។

ឈុនលី ៖ ៧៤ ម៉េចទៅអ៊ឹរញ៉េរញ៉ៃម៉េចទៅ?

ធី ៖ រញ៉េរញ៉ៃដូចថាពួកខ្ញុំចេញទៅរីមងនៅទន្លេចិនវាលបបាញ់ លប់ផ្លោង ។

ឈុនលី ៖ លបបាញ់អ្នកនេសាទ?

ធី ៖ បាទ!

ឈុនលី ៖ ហើយអ៊ឹគេចដែរ?

ធី ៖ គេច តែពួកខ្ញុំមានអាវុធ គេឲ្យអាវុធការពារ ។

ឈុនលី ៖ បាញ់វិញដែរ?

ធី ៖ បាទ!មានកាំភ្លើងទប់ទល់វិញ ។

ឈុនលី ៖ ហើយខ្មែរក្រហមរត់អស់ទៅ?

ធី ៖ វានៅ ដូចថាវានៅក្បែរព្រៃដាក់ទោបះដើងដែរ ប្រើទូកសម័យនោះប្រើទូកនៅទន្លេណាសនាង វាក៏ប្រើទូក យើងក៏ប្រើទូក ។

ឈុនលី ៖ ហើយម៉េចទៀតទៅដល់ពេលចូលដល់៧៥?

ធី ៖ ចូលដល់៧៥មកក៏ខ្ញុំភៀសខ្លួនមកវិញមកនៅភូមិកំណើតវិញ ។

ឈុនលី ៖ ម៉េចបានមកនៅភូមិកំណើតវិញ?

ធី ៖ ដោយសារនៅនោះវាជ្រួលច្របល់ហើយ លុយវាអត់មានតំលៃ ។

ឈុនលី ៖ ហើយម៉េចទៀតទៅពេលមកដល់ស្រុកភូមិវិញ?

ធី ៖ ពេលមកដល់ស្រុកភូមិវិញរំលងបានប្រហែលបីខែចាប់ផ្ដើមពួក ប៉ុល ពត ចូល ។

ឈុនលី ៖ ចូលមកម៉េចទៅ?

ធី ៖ ចូលមកចាប់ផ្ដើមជម្លៀសចេញពីភូមិ ។

ឈុនលី ៖ ទៅណា?

ធី ៖ មកនៅចាលើយើងឃុំទឹកជោរ ។

ឈុនលី ៖ ចាលើ ឃុំទឹកជោរ ។

ធី ៖ បាទ!

ឈុនលី ៖ ហើយទៅកន្លែងនោះធ្វើអី?

ធី ៈ អត់ឲ្យធ្វើអីទេគឺថាឲ្យយើងទៅនៅឯកោប្រហែលជាបីបួនយប់ ។

ឈុនលី ៈ នៅខ្ទមតើហ្អី?

ធី ៈ នៅបរទេះទៅអាខ្វះទៅដើរទៅ ។

ឈុនលី ៈ ជុំគ្នា?

ធី ៈ បាទ!ជុំគ្នាម៉ាភូមិ ។

ឈុនលី ៈ តែយើងនៅហ្នឹងនៅរបៀបផ្ទះមួយៗទេមិនមែនសហករណ៍ទេ?

ធី ៈ អត់ទេ យកយើងទៅរបៀបដាក់ចោលក្នុងព្រៃតែម៉ង ។

ឈុនលី ៈ ចឹងទៅនៅក្នុងព្រៃ?

ធី ៈ បាទ! នៅក្នុងព្រៃ ។

ឈុនលី ៈ ចុះបានអីហូបទៅ?

ធី ៈ កាលនោះកុំតែបានដាក់អង្ករដាក់អីទៅ ។

ឈុនលី ៈ ចឹងគេអត់មានចែកអីឲ្យហូបទេ?

ធី ៈ អត់ទេបានលួចដាក់ទៅបានៗហូប ។

ឈុនលី ៈ ប្រហែលប៉ុន្មានថ្ងៃទៅ?

ធី ៈ បួនប្រាំថ្ងៃ ឲ្យត្រលប់មកភូមិវិញមិនទាន់បានសំរាកផង ឲ្យចេញទៀត ។

ឈុនលី ៈ ទៅណាទៀត?

ធី ៈ នៅចារក្រោមទៀតនាង!

ឈុនលី ៈ ទៅនៅចារលើ ចេញពីចារលើទៅចារក្រោមទៀត?

ធី ៈ បាទ!មកចារក្រោម ។

ឈុនលី ៈ ហើយម៉េចទៀតទៅធ្វើអីទៀតនៅចារក្រោម?

ធី ៈ ទៅនោះវាឲ្យទៅបណ្តោយអត់មានថាធ្វើអីៗទេ ។

ឈុនលី ៈ ចុះគេប្រាប់ថាម៉េច?

ធី ៈ អត់មានប្រាប់ទេ ទៅៗក៏ខ្ញុំទៅនៅខាងភូមិនេះ ទៅៗវាបង្អត់បាយទឹកអត់ឲ្យបាយស៊ីតែម៉ង ។

ឈុនលី ៈ គេអត់ឲ្យធ្វើការទេចឹង?

ធី ៈ ធ្វើ ចាប់ផ្តើមទៅបានឲ្យធ្វើស្រែ ឲ្យធ្វើស្រែប៉ែកខាងឪម៉ាល់ផ្លូវកាត់ ។

ឈុនលី ៈ ឪម៉ាល់ផ្លូវកាត់?

ធី ៖ បាទ!ឪម៉ាល់ផ្លូវកាត់ ។

ឈុនលី ៖ អាហ្នឹងជាអីគេ? ភូមិ ឃុំ?

ធី ៖ ឃុំ ទេឃុំទឹកជោរដែរ ។

ឈុនលី ៖ ទៅធ្វើស្រែ?

ធី ៖ បាទ!

ឈុនលី ៖ ធ្វើស្រែការងារអឺធ្វើអីគេ ភ្ជួរ?

ធី ៖ ភ្ជួរ ដកស្ទូង ។

ឈុនលី ៖ ហើយរួចហើយទៅណាទៀត?

ធី ៖ មកវិញក៏គេឲ្យលើក ។

ឈុនលី ៖ នៅហ្នឹងយូរទេ?

ធី ៖ នៅបានម៉ាវស្សា ។

ឈុនលី ៖ ហើយទៅណាទៀត?

ធី ៖ ឡើងវិញមកនៅចារក្រោម ។

ឈុនលី ៖ អាមិញហ្នឹងនៅចារលើនៅឡើយទេ?

ធី ៖ បាទ!វិលទៅវិលមក ។

ឈុនលី ៖ ទៅចារក្រោមហ្នឹងធ្វើអីគេទៅ?

ធី ៖ ឲ្យមកនៅចារក្រោម ឲ្យឪពុកម្ដាយខ្ញុំទៅនៅចារក្រោមខ្ញុំនៅជាមួយគាត់បានប្រហែលម៉ាខែខ្ញុំចេញចល័ត ។

ឈុនលី ៖ នៅជុំគ្នាជាមួយគាត់?

ធី ៖ បាទ!ចំនួនម៉ាខែ ។

ឈុនលី ៖ ហើយចូលចល័ត?

ធី ៖ បាទ!

ឈុនលី ៖ ចល័តអីគេ ចល័តស្រុកឬតំបន់?

ធី ៖ ចល័តតំបន់ ។

ឈុនលី ៖ តំបន់ប្រាំ?

ធី ៖ បាទ!

ឈុនលី ៖ កាលនោះអ្នកណាគេគ្រប់គ្រងតំបន់ប្រាំ?

ធី ៖ ដែលនៅគ្រប់គ្រងពួកខ្ញុំខាងចល័តនោះ?

ឈុនលី ៖ ចាស!

ធី ៖ នែ!ឈ្មោះលោក តាវ៉ាល់ ។

ឈុនលី ៖ តាវ៉ាល់?

ធី ៖ បាទ!តាវ៉ាល់ ។

ឈុនលី ៖ កាចទេតាវ៉ាល់?

ធី ៖ ហួស!កាចណាស់ ។

ឈុនលី ៖ គ្រប់គ្រងចល័ត តាវ៉ាល់?

ធី ៖ បាទ!

ឈុនលី ៖ ចុះអ្នកណាលើ តាវ៉ាល់ទៀត?

ធី ៖ អត់ស្គាល់ទេនាង ។

ឈុនលី ៖ តាម៉ោងហ្អី?

ធី ៖ ធ្លាប់ឮដែរ ។

ឈុនលី ៖ អីចឹងអឹនៅក្រោមការគ្រប់គ្រងរបស់ តាវ៉ាល់?

ធី ៖ បាទ!

ឈុនលី ៖ ហើយធ្វើអីទៅ?

ធី ៖ ខ្ញុំដឹកនាំកុមារឲ្យរែកដី?

ឈុនលី ៖ មេកង?

ធី ៖ បាទ!

ឈុនលី ៖ ចឹងគេតែងតាំងឲ្យពូធ្វើមេកង?

ធី ៖ បាទ! ប្រធានកងកុមារ ។

ឈុនលី ៖ ធ្វើអីខ្លះទៅអឹ កុមារប៉ុន្មាននាក់ទៅ?

ធី ៖ កុមារ១០០នាក់ ។

ឈុនលី ៖ ហើយយើងដឹកនាំធ្វើអីខ្លះទៅ?

ធី ៖ ដឹកនាំឲ្យរែកដី ។

ឈុនលី ៖ កុមារអាយុប៉ុន្មាន?

ធី ៖ អាយុ១៥ ១៦ ។

ឈុនលី ៖ ឲ្យវែកដីហើយអីទៀត?

ធី ៖ ប៉ុណ្ណោះឯង ។

ឈុនលី ៖ ចុះអ៊ំធ្វើអីដែរ អ៊ំធ្វើការដែរ?

ធី ៖ ធ្វើ ។

ឈុនលី ៖ មេកងវែកដែរ?

ធី ៖ ទេ ធ្វើទាំងអស់តែគ្នា ។

ឈុនលី ៖ ចឹងអ៊ំវែកជាមួយក្មេងៗ?

ធី ៖ បាទ!

ឈុនលី ៖ ហើយម៉េចទៀតទៅ វែកដីធ្វើអីទៅ?

ធី ៖ វែកធ្វើទំនប់ ។

ឈុនលី ៖ ទំនប់ឯណាទៅ?

ធី ៖ ធ្វើទំនប់យើងទំនប់ភ្នំកំបោរ...

ឈុនលី ៖ ទំនប់ភ្នំកំបោរហ្នឹងទំនប់តាវ៉ាល់ហ្អី?

ធី ៖ ទំបន់តាវ៉ាល់ ។

ឈុនលី ៖ គេហៅតាំងពីនោះមកហ្អី?

ធី ៖ បាទ!

ឈុនលី ៖ ទំនប់ហ្នឹងនៅក្នុងភូមិអីគេ ។

ធី ៖ នៅក្នុងស្រុកព្រះនេត្រព្រះ?

ឈុនលី ៖ ភូមិអីគេ?

ធី ៖ ព្រះនេត្រព្រះ ។

ឈុនលី ៖ ភូមីអីគេ?

ធី ៖ ភូមិកំបោរចាប់ពីកំបោរដល់ស្រែះខាងកើត មកដល់ប៉ោយសំរោង ។

ឈុនលី ៖ ពីណាទៅណាទៅ?

ធី ៖ ពីកំបោរមកដល់ស្រែះខាងកើត បត់ពីស្រែះខាងកើតមកដល់ភូមិប៉ោយសំរោងយើងនេះ ។

ឈុនលី ៖ ប៉ោយសំរោង បីភូមិ?

ធី ៖ បាទ!

ឈុនលី ៖ ចំងាយប៉ុន្មានទៅ?

ធី ៖ ចំងាយ១៣គីឡូ ។

ឈុនលី ៖ គ្រាន់តែទំនប់ហ្នឹង?

ធី ៖ បាទ!

ឈុនលី ៖ ទទឹងវាប៉ុន្មានទៅ?

ធី ៖ ទទឹងថា៥ម៉ែត្រទៅនាង!

ឈុនលី ៖ ហើយក្មេងៗចឹងម្នាក់គេចែកឲ្យកាប់ប៉ុន្មានទៅ?

ធី ៖ កាលនោះធ្វើរួមគ្នាទី១ តែគេដាក់អាដែងបណ្តោយទំបន់ ធ្វើរួមតែគេ ទំនប់នោះគេដាក់ថាប៉ុន្មានៗឲ្យយើងធ្វើក្នុងម៉ាកង ។

ឈុនលី ៖ ចុះដូចកងអីម៉ារយនាក់នោះ?

ធី ៖ បាទ ១០០នាក់ចឹងគេដាក់១០ម៉ែត្រ ។

ឈុនលី ៖ ១០០ម៉ែត្រ១០នាក់គិចម្ទេះ?

ធី ៖ បណ្តោយណាស បណ្តោយ១០ម៉ែត្រ ជើងទេ១០ម៉ែត្រ ។

ឈុនលី ៖ យ៉ាងម៉េចទៅអាហ្នឹងជើងទេ?

ធី ៖ ទេ ជើងទេធម្មតាវាធំក្រោមណាសនាង ទំនប់ ។

ឈុនលី ៖ ធំលើហ្អី?

ធី ៖ ទេ តូចលើ ។

ឈុនលី ៖ ធំក្រោមចឹងមិនអីចេះ អីចឹងវាមិនបាក់ដី?

ធី ៖ ទេ វាងផ្កាត្រកួន ។

ឈុនលី ៖ ផ្កាត្រកួនឡើងលើឬចុះក្រោមអីចេះ?

ធី ៖ ស្រួចលើ ធម្មតាទំនប់ជើងធំបានជាប់ ។ ឧទាហរណ៍ថាអានេះជើងទំនប់ចឹងគេធ្វើស្រួចឡើងលើ ។

ឈុនលី ៖ អស!អាហ្នឹងនៅលើដីទេតើ!

ធី ៖ នៅលើដី

ឈុនលី ៖ គេអត់គិតអាក្នុងជីកន្លែងយើងជីកទេ ។

ធី ៖ អត់ទេ ។

ឈុនលី ៖ ១០០នាក់បណ្តោយប៉ុន្មាន?

ធី ៖ បណ្ដោយ២០ ។

ឈុនលី ៖ ១០០នាក់ បណ្ដោយ២០ម៉ែត្រ ទទឹង?

ធី ៖ ទទឹង៨ ។

ឈុនលី ៖ ដើងទេវា ដើងទេហ្នឹងហើយទទឹង!

ធី ៖ បាទ! ដើងទេហ្នឹងទទឹង លើគ្រាំ ។

ឈុនលី ៖ អាហ្នឹងក្នុងម៉ាថ្ងៃ?

ធី ៖ បាទ!

ឈុនលី ៖ ហើយធ្វើហើយដែរអ៊ី?

ធី ៖ ហូស! ហើយតែយ៉ាប់ណាស់នាង ជួបការលំបាក ហើយដល់ម៉ោង៥ ៦បានហើយ ។

ឈុនលី ៖ ហើយគេឲ្យហូបអី?

ធី ៖ ហូបបបរ ។

ឈុនលី ៖ អត់ឲ្យហូបបាយទេ?

ធី ៖ ទេ ។

ឈុនលី ៖ បបរប៉ុណ្ណា?

ធី ៖ បបរម៉ាកាតូយើងនេះ ។

ឈុនលី ៖ ម៉ាស្រាក់?

ធី ៖ ម៉ាកាតូ ។

ឈុនលី ៖ សំរាប់ប៉ុន្មាននាក់?

ធី ៖ ម្នាក់ឯង ។

ឈុនលី ៖ ពេញ?

ធី ៖ ម៉ាល្មម ។

ឈុនលី ៖ ហើយរាវទេ?

ធី ៖ រាវ ។

ឈុនលី ៖ ហើយអត់មានម្ហូបអីទេ?

ធី ៖ អត់ ។

ឈុនលី ៖ មានអំបិល?

ធី ៖ បាទ! បើយើងឆ្មៀតដីកកណ្ដុរដីកអីតាមវាលទៅ ។

ឈុនលី ៖ ដីកកណ្ដុរ?

ធី ៖ ដីកកណ្ដុរហើយបើល្អែងត្រៀបត្រីតាមបឹងតាមបួរអីសំបូរណាស់ពីដើមមេញចាប់នឹងដៃក៏បានដែរ ។

ឈុនលី ៖ ហើយចាប់គេអត់ថាអីទេ?

ធី ៖ ទេ កុំឲ្យដុតពីការផ្សារ ដុតពីការផ្សារអាចឆ្មៀតបាន ។

ឈុនលី ៖ ហើយមានទឹកហូបដែរ?

ធី ៖ បាទ!កាលនៅជាមួយកុមារមាន ។

ឈុនលី ៖ ទឹកយកពីណាមក?

ធី ៖ ទឹកដងហូបខ្លួនឯងតាមបឹង ។

ឈុនលី ៖ ហើយពេលយប់ឡើងចឹងយើងទៅស្នាក់នៅឯណា?

ធី ៖ ដេកនៅតាមវាល ដេកនៅតាមដើងទំនប់ ។

ឈុនលី ៖ ចុះបើត្រូវភ្លៀងត្រូវអីនោះ?

ធី ៖ មិនដឹងធ្វើម៉េច ។

ឈុនលី ៖ អត់មានរោងអត់មានដើមឈើអីទេ?

ធី ៖ អត់មានទេនៅកណ្ដាលវាលតែម្ដង ។

ឈុនលី ៖ ទៅធ្វើខែប្រាំង?

ធី ៖ ធ្វើទាំងប្រាំងទាំងវស្សា ។

ឈុនលី ៖ អីចឹងមិនត្រូវភ្លៀងត្រូវថ្ងៃអីហើយ?

ធី ៖ បាទ! ដេកតែនឹងដី ។

ឈុនលី ៖ ប្រហែលប៉ុន្មានបានហើយទៅ?

ធី ៖ កំលាំងក៏មិនច្រើនដែរប្រហែល៨០០នាក់ ។

ឈុនលី ៖ អ្នកទៅដីកហ្នឹងច្រើនទេអី?

ធី ៖ ប្រហែល៨០០នាក់រាប់ទាំងកម្មាភិបាល ។

ឈុនលី ៖ ៨០០នាក់ទាំងកម្មភិបាល?

ធី ៖ បាទ!

ឈុនលី ៖ ចុះដូចអ៊ីមេកងអីចឹងគេចាត់ចូលក្នុងកម្មាភិបាលដែរអត់?

ធី ៖ អត់ទេ ។

ឈុនលី ៖ ត្រឹមប៉ុណ្ណាដែលគេចាត់ចូលកម្មាភិបាល?

ធី ៖ ចូលកម្មាភិបាលចូលវីរៈហើយ វីរៈសេនាធំហើយ បើមិនសំណំអីសំឡុតដែរហើយ ។

ឈុនលី ៖ យើងបានសំឡុតដែរ?

ធី ៖ បាទ!

ឈុនលី ៖ ៧០០ ៨០០នាក់ប្រហែលប៉ុន្មានខែអឹ?

ធី ៖ ប្រហែលម៉ាខែ វៃខ្ញុំផណាស់ទាំងយប់ទាំងថ្ងៃ ។

ឈុនលី ៖ មានធ្វើយប់ទៀត?

ធី ៖ បាទ!

ឈុនលី ៖ ចុះម៉េចមានធ្វើយប់ទៀតបើគេចែកប្រវែងអីត្រឹមត្រូវហើយ?

ធី ៖ អត់ទេ យប់គេប្រើយើងផ្សេង ។

ឈុនលី ៖ វាស់ផ្សេងទៀត?

ធី ៖ បាទ!

ឈុនលី ៖ ចុះម៉ាថ្ងៃឲ្យបាយប៉ុន្មានពេល?

ធី ៖ តែពីរពេលទេ ។

ឈុនលី ៖ ធ្វើការដល់យប់ទៀត?

ធី ៖ បាទ!ហូបបបរហើយដល់ម៉ោង៦ ៧ ទៅទៀត ។ អាណាខ្ញុំក់មាន់ឲ្យដឹកដៃគ្នាទៅទៀត ។

ឈុនលី ៖ ចុះដល់ម៉ោងប៉ុន្មានបានឈប់?

ធី ៖ ម៉ោងចាប់ពីម៉ោង៧ដល់ម៉ោងដប់ ។

ឈុនលី ៖ កាលនោះអឹខ្ញុំក់មាន់ដែរអត់?

ធី ៖ អត់ទេ ។

ឈុនលី ៖ ចុះក្មេងៗហ្នឹងខ្ញុំក់មាន់ច្រើន?

ធី ៖ បាទ!

ឈុនលី ៖ ហើយដឹកដៃគ្នាទៅ ចឹងមិនយឺតៗហើយ?

ធី ៖ មិនដឹងធ្វើម៉េចទេនាង!

ឈុនលី ៖ ហើយគេវាស់ដូចពេលថ្ងៃដែរអត់?

ធី ៖ អត់ទេ អ្នកខ្ញុំក់មាន់គេឲ្យនៅដង្ហែគ្នាហុចតគ្នាឡើងលើទំនប់ អ្នកណាដឹកៗទៅ ។

ឈុនលី ៖ ចេះតែហុចទៅមើលអត់ឃើញផង?

ធី : បាទ! ឈរបន្តគ្នា ។

ឈុនលី : ភាគច្រើនអ្នកនៅស្រុកណាជីកទំនប់ហ្នឹង?

ធី : បើនិយាយដល់ទៅថាមានលាយបងប្អូននៅទីក្រុងភ្នំពេញច្រើនដែរកាលនោះ ។

ឈុនលី : ភ្នំពេញប្រជាជនថ្មី ហើយលាយចាស់ដែរ?

ធី : បាទ! ប្រជាជនចាស់ហ្នឹងអ្នកនៅព្រះនេត្រព្រះ ។

ឈុនលី : ហើយភាគច្រើនប្រជាជនថ្មីឈឺទេ?

ធី : ឈឺ ។

ឈុនលី : ភាគច្រើនប្រជាជនថ្មីហ្នឹងហ្អី?

ធី : បាទ!

ឈុនលី : ភាគច្រើនឈឺអីគេ?

ធី : ឈឺមួល ។

ឈុនលី : រាក?

ធី : បាទ! រាកមួល ។

ឈុនលី : ចុះមានអ្នកខ្លះធ្វើការៗស្លាប់ដែរទេ?

ធី : បាទ!

ឈុនលី : ឈឺអត់រកថ្នាំទេ?

ធី : អត់ មានថ្នាំអីគ្នាឈឺដេកតែតាមដុបតាមព្រៃឲ្យលេបតែថ្នាំអាចម៍ទន្សាយ ។

ឈុនលី : ភាគច្រើនស្លាប់តែអ្នកថ្មី?

ធី : បាទ!

ឈុនលី : ដូចកំពុងធ្វើការៗស្លាប់អីមានដែរទេ?

ធី : អត់មានទេ មានតែអ្នកកើតខ្យល់ ។

ឈុនលី : ហើយចុះអ្នកស្លាប់ហ្នឹងទាល់តែកំរិតណាទៅបានស្លាប់?

ធី : អ្នកដែលស្លាប់នោះដូចថាចូលដល់វ័យកំលោះហើយ អានោះខ្ញុំដឹកនាំផ្នែកខាងត្រពាំងថ្ម តែម្តង ។

ឈុនលី : ចឹងហើយអានេះហើយ?

ធី : បាទ!

ឈុនលី : ហើយអានេះទៅនោះបណ្តោយហ្អី?

ធី ៖ បាទ!

ឈុនលី ៖ ឆ្នាំណាទៅ?

ធី ៖ ៧៧ ។

ឈុនលី ៖ ១៩៧៧?

ធី ៖ បាទ!

ឈុនលី ៖ ក្រោមការគ្រប់គ្រងរបស់អ្នកណាគេ?

ធី ៖ ក្រោមលោកតាវ៉ាល់ ។

ឈុនលី ៖ ចុះពេលណាបានពួកនិរតីចូលមក?

ធី ៖ ឆ្នាំ៧៧កន្លះ ។

ឈុនលី ៖ កាលនោះអ៊ំអាយុប៉ុន្មានហើយ?

ធី ៖ ២០គត់ ។

ឈុនលី ៖ អាពេលទៅដឹកនាំត្រពាំងថ្ម?

ធី ៖ ១៩ ។

ឈុនលី ៖ អ៊ីចឹងគេឲ្យកាន់កូនចៅប៉ុន្មាននាក់?

ធី ៖ កាន់កងដែរ ១០០នាក់ ។

ឈុនលី ៖ ១០០នាក់ដែរហើយភាគច្រើននាក់នោះមកពីណា?

ធី ៖ អ្នកភ្នំពេញ ។

ឈុនលី ៖ ហើយមានអ្នកស្រុកព្រះនេត្រព្រះដែរ?

ធី ៖ បាទ!

ឈុនលី ៖ ភាគច្រើនស្រីៗឬយ៉ាងម៉េច,

ធី ៖ ស្មើគ្នា ។

ឈុនលី ៖ ចុះអ្នកដែលទៅព្រះនេត្រព្រះហ្នឹងគេហៅកងអី?

ធី ៖ កងចល័ត ។

ឈុនលី ៖ តំបន់ឬក៏ស្រុក?

ធី ៖ តំបន់ ។

ឈុនលី ៖ តំបន់ទៀត?

ធី ៖ បាទ!តំបន់ប្រាំយើងនេះ ។

ឈុនលី ៈ ចុះក្រែងចល័តហ្នឹងគេបែងចែកប្រភេទទៀតហ្អី?

ធី ៈ បែកចែកទៅតាមស្រុក ស្រុកមណ្ឌលបុរីផ្សេងទៀត ស្រុកព្រះនេត្រព្រះផ្សេង ។

ឈុនលី ៈ តែគេមានបែងចែកជាចល័តស្រុក ចល័តឃុំទៀតហ្អីព្រោះខ្ញុំឮគេថាចល័តតំបន់អត់ទៅណាទេនៅតែក្នុងភូមិហើយចល័តស្រុកឬចល័តឃុំត្រូវទៅធ្វើការនៅត្រពាំងថ្មចឹងមែនហ្អីអ៊ំ?

ធី ៈ បើដល់យូរទៅមើលទៅទំនប់នោះវាចួបកាលំបាកច្រើនចឹងហៅទៅទាំងឃុំទាំងអីហ្នឹងឯងទៅជួយគ្នានៅទំនប់ត្រពាំងថ្មទៅរួមគ្នាជាមួយចល័តតំបន់ ។

ឈុនលី ៈ ឆ្នាំ៧៧?

ធី ៈ បាទ!

ឈុនលី ៈ ចុះពេលអ៊ំនាំកងទៅហ្នឹងមានគេធ្វើមុនហើយឬនៅ?

ធី ៈ អត់ទេ ។

ឈុនលី ៈ នៅវាលនៅឡើយ?

ធី ៈ នៅវាលនៅឡើយ ។

ឈុនលី ៈ កាលនោះអ្នកណាអ្នកឲ្យធ្វើទំនប់ត្រពាំងថ្ម?

ធី ៈ នៅតែមេខ្ញុំតែមួយហ្នឹង តាវ៉ាល់ ។

ឈុនលី ៈ ចុះដំបូងគេមានអ្នកមកគូសប្លង់អីត្រឹមត្រូវទេ?

ធី ៈ អត់មានទេ ។

ឈុនលី ៈ អ្នកណាគេអ្នកនាំគំនិតធ្វើទំនប់ហ្នឹង?

ធី ៈ ទំនប់កំបោរយើងទីមួយហ្នឹង?

ឈុនលី ៈ អត់ទេ ទំនប់ត្រពាំងថ្ម ។

ធី ៈ ខ្ញុំអត់ដឹងទេ តែមេដឹកនាំឃើញតែលោក តាវ៉ាល់ ។

ឈុនលី ៈ តាវ៉ាល់ ហ្នឹងរូបរាងយ៉ាងម៉េចទៅ?

ធី ៈ រូបរាងគាត់ស្ដើងខ្ពស់ដូចតានោះ ។

ឈុនលី ៈ កាច?

ធី ៈ បាទ!ប្រមុះស្រួចដូចមីនាងឯងចឹង ។

ឈុនលី ៈ ហើយពេលទៅដំបូងចឹងភាគច្រើនស្រីៗទេតើហ្អី?

ធី ៈ អត់ទេប្រុសតាមប្រុសស្រីតាមស្រី ខ្ញុំកាន់ខាងយុវជនប្រុសៗ ។

ឈុនលី ៈ ចឹងស្រីៗមេគេស្រីហ្អី?

ធី ៖ បាទ!

ឈុនលី ៖ អត់ឲ្យនៅជាមួយគ្នាទេចឹង?

ធី ៖ នៅក្បែរៗគ្នាណាស់នាង គ្រាន់តែថាមួយផ្ទះស្រីមួយផ្ទះប្រុសតែកាលនោះនៅតែខ្ទម ។

ឈុនលី ៖ ទៅដល់នោះគេមានខ្ទមមានអី?

ធី ៖ បាទ!

ឈុនលី ៖ កាលនោះឆ្នាំ៧៧ដើមឆ្នាំហ្អី?

ធី ៖ ចុងឆ្នាំ ។

ឈុនលី ៖ ហើយពេលទៅដល់ដំបូងធ្វើម៉េចខ្លះទៅអ៊ំបើដីវាលស្មើចឹង?

ធី ៖ ទៅដល់ដំបូងគេវាស់គេតំរង់ ។

ឈុនលី ៖ ប្រវែងប៉ុន្មាន?

ធី ៖ អូស!ទំនប់ហ្នឹងធំណាស់ ។

ឈុនលី ៖ គំរោងគេធ្វើប៉ុន្មានម៉ែត្រទៅ ប៉ុន្មានគីឡូទៅ?

ធី ៖ ត្រពាំងថ្មធ្វែលទៅដល់ចង់កូនខ្វែង ។

ឈុនលី ៖ កាត់ភូមិណាខ្លះ?

ធី ៖ ដូចធ្វើចាប់ពីត្រពាំងថ្មទៅលិចបណ្តោយ ។

ឈុនលី ៖ កាត់តាមភូមិណាទៀត?

ធី ៖ អត់មាន ទំនប់នោះធ្វើពីក្បាលភូមិកាត់ទៅវាលបណ្តោយ ។

ឈុនលី ៖ វាលនោះចូលភូមិមួយទៀត?

ធី ៖ អត់ទេ ។

ឈុនលី ៖ ចុះកូនខ្វែងនៅភូមិអីគេ?

ធី ៖ ភ្នំកូនខ្វែងបណ្តោយ ។

ឈុនលី ៖ រាងវាយ៉ាងដម៉េចទៅទំនប់?

ធី ៖ ហួស!រាងវាធំណាស់ ដូចដីកធ្វើអាងបណ្តោយ អាងនោះពីសម័យបុរាណផ្លូវកាត់ទៅអង្គរ

ឈុនលី ៖ ធ្វើអាងនោះកាត់ទៅអង្គរ?

ធី ៖ បាទ!ធ្វើកាត់ទៅអង្គរ អានេះផ្លូវពីបុរាណមកណាស់ដល់នេះគេយកយើងទៅធ្វើអាដែងពីលើផ្លូវបុរាណ ។

ឈុនលី ៖ ផ្លូវបុរាណហ្នឹងទៅអង្គរ?

ធី ៖ បាទ!តែពួកខ្ញុំទៅត្រឹមត្រពាំងថ្ម ។

ឈុនលី ៖ យើងគេសាងសង់ហ្នឹងយកតាមគំរូផ្លូវចាស់?

ធី ៖ បាទ!តាមគំរូផ្លូវចាស់ ។

ឈុនលី ៖ ដើម្បីអីគេទៅ?

ធី ៖ ទេ កាលនោះគេហៅអាង អាងត្រពាំងថ្មៗកូនខ្វែង ។

ឈុនលី ៖ ចុះបើកគំរូផ្លូវចាស់ចឹងកន្លែងនោះមានប្រាសាទមានអីដែរអត់?

ធី ៖ មាន ។

ឈុនលី ៖ ប្រាសាទអីគេ?

ធី ៖ ប្រាសាទនៅឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះប្រាសាទអីទេ...

ឈុនលី ៖ តែពេលអឹទៅមានប្រាសាទនៅហ្នឹងទេ ដូចថាមានកំទេចកំទីអីទេ?

ធី ៖ ទៅឃើញតែកំទេចកំទីជាតិអំបែងចាន បញ្ចារ៉ុងអី ជាតិអំបែងក្អមអី ។

ឈុនលី ៖ តាមពិតគោលបំណងគេជីកអាហ្នឹងធ្វើអី?

ធី ៖ ជីក សព្វថ្ងៃបើនិយាយទៅកើតទៅជាផ្លូវខ្វាត់ខ្វែងហើយបើអាណាធំដែលប្រើកើត មានកើតថ្នល់កើតអី ។

ឈុនលី ៖ តែកាលជំនាន់នោះធ្វើក្នុងគោលបំណងអី?

ធី ៖ គេប្រើយើង ។

ឈុនលី ៖ គេទុកធ្វើស្រែប្មក៏ធ្វើអី?

ធី ៖ ធ្វើស្រែហ្នឹងឯង ធ្វើទំនប់ធ្វើភ្លឺ ធ្វើប្រឡាយធ្វើស្រែ ។

ឈុនលី ៖ វាលហ្នឹងវាលគេធ្វើស្រែហ្អីពីដើមមក?

ធី ៖ បាទ!

ឈុនលី ៖ ចុះយើងជីកទំនប់ហ្នឹងជីកលើស្រែ?

ធី ៖ ជីកលើស្រែ អត់មានប្រកាន់ដីគេដីឯងឯណាកាលនោះ ។

ឈុនលី ៖ ហើយមនុស្សប៉ុន្មាននាក់ទៅធ្វើទំនប់ត្រពាំងថ្ម?

ធី ៖ ហូស!ច្រើនណាស់ ចូលពីរពាន់នាក់ហើយ ។

ឈុនលី ៖ តិចម្លេះអឹអត់ដល់ម៉ឺនទេ?

ធី ៖ អត់ទេ បើដល់ម៉ឺននោះ ហូស!តិចណាស់ហ្អីមនុស្ស?

ឈុនលី ៖ ចុះប៉ុន្មានកងទៅ?២០កង?

ធី : ២០កង វាមិនតិចទេ ទំរាំកសាងហើយជិតពីរឆ្នាំងាប់បណ្ដើដល់យូរៗទៅនៅតិច...

ឈុនលី : គំរោងគេធ្វើរយៈពេលប៉ុន្មាន?

ធី : ទំនប់នោះ?

ឈុនលី : ចាស!

ធី : ឧទាហរណ៍ថាគេត្រូវធ្វើបីខែ គេបង្ខំឲ្យយើងធ្វើតែម៉ាខែ ។

ឈុនលី : គំរោងធ្វើបីខែ?

ធី : បីខែ ។

ឈុនលី : ចុះរយៈពេលប៉ុន្មានបានធ្វើហើយអាជាក់ស្ដែង?

ធី : ដល់គេប្រើយើងខ្លាំង យើងមិនធ្វើតាមគេឯណាខ្លាចគេយកទៅវ៉ៃចោលម្លោះហើយធ្វើទាំងយប់ទាំងថ្ងៃតាមគេ ។ ធ្វើរួចប្រហែលម៉ាខែកន្លះ ដូចថាចិត្តយើងថាបីខែរួចតែអង្គការដឹកនាំយើងថាឲ្យរួចក្នុងម៉ាខែ ។

ឈុនលី : ហើយអាងនោះទទឹងបណ្ដោយ កំពស់ប៉ុន្មានទៅ?

ធី : កំពស់៥ម៉ែត្រ ។

ឈុនលី : ៥ម៉ែត្រឡើងលើ?

ធី : បាទ!៥ម៉ែត្រ ។

ឈុនលី : បណ្ដោយ?

ធី : បណ្ដោយចូលប្រហែល២០គីឡូ ថា២០គីឡូទៅនាង ។

ឈុនលី : ជើងវានោះ ទទឹងវានោះ?

ធី : ជើង២០ម៉ែត្រ ។

ឈុនលី : ច្បាស់ទេអ៊ឹអាហ្នឹង?

ធី : បាទ ធំណាស់ ។

ឈុនលី : អ្នកណាអ្នកវាស់វែង?

ធី : អានោះគឺថាមានដូចថាគេដាក់គំរោងមកក៏យើងអ្នកវាស់ខ្លួនឯងទៅ ។

ឈុនលី : អ៊ឹអ្នកវាស់?

ធី : បាទ! ជួយវាស់គ្នាឲ្យតែមេកង

ឈុនលី : ចុះអ៊ឹគេវាស់ចែកគ្នាយ៉ាងម៉េចទៅ?

ធី : ដៃរម្នាក់បីម៉ែត្រ ។

ឈុនលី ៈ បីម៉ែត្រគីប?

ធី ៈ បាទ!

ឈុនលី ៈ ម៉ាថ្ងៃ?

ធី ៈ ម៉ាថ្ងៃ ។

ឈុនលី ៈ ចែកគ្នាស្មើចឹងអត់មានអ្នកណាមួយ ពីរអីទេ?

ធី ៈ អត់ទេ ។

ឈុនលី ៈ គេគិតតាមកំលាំងដែរទេ?

ធី ៈ អត់ ទូទៅ ។

ឈុនលី ៈ អ្នកណាអ្នកវាស់?

ធី ៈ ប្រធានកង ។

ឈុនលី ៈ ប្រធានកងឈ្មោះអីគេ?

ធី ៈ ទេ គេដាក់កំរិតមកប្រធានកង ខ្ញុំអីហ្នឹងអ្នកវាស់ទៅ ។

ឈុនលី ៈ បីៗ ហើយភាគច្រើនអាយុប៉ុន្មាននៅក្រោមការគ្រប់គ្រងបស់អ៊ឹ?

ធី ៈ ១៧ ១៨ ។

ឈុនលី ៈ ម៉ាថ្ងៃឲ្យហើយ?

ធី ៈ បាទ!

ឈុនលី ៈ ហើយភាគច្រើនហើយស្មើណា?

ធី ៈ បើថាអ្នកដែលខស្យាទៅម៉ោងបី ។

ឈុនលី ៈ ចុះមានពេលណាធ្វើអត់ហើយទេ?

ធី ៈ បាទ!

ឈុនលី ៈ អត់ហើយឲ្យឈប់ដែរអត់?

ធី ៈ អត់ឲ្យឈប់ទេ ធ្វើវាល់ល្ងាច ។

ឈុនលី ៈ ចុះបាយទឹក?

ធី ៈ បាយទឹកវាល់ចែកគ្នាម៉ាកាតូដូចគ្នា ។

ឈុនលី ៈ អត់ឲ្យឡើងម៉ងហ្អីអត់ហើយ?

ធី ៈ បាទ!អត់ឲ្យឡើងទាល់តែដល់ពេលចែកបាយបានឡើងបាន ។

ឈុនលី ៈ ចុះបើអ្នកអត់ហើយដល់ល្ងាចដល់យប់ទៀត ។

ធី ៖ អត់ហើយអានេះស៊ីសង់នឹងយើងជាមេកោយយើងស្រណោះគ្នា យើងយល់គ្នាទៅក៏អត់ទោសឲ្យគ្នា លុបលាងទៅ ។

ឈុនលី ៖ អីចឹងអ៊ំចិត្តល្អជាមួយគេ?

ធី ៖ បាទ ។

ឈុនលី ៖ ហូបបាយម៉េចទៅអ៊ំ?

ធី ៖ បាយម៉ាកាតូ ។

ឈុនលី ៖ ប៉ុណ្ណាទៅ?

ធី ៖ រសោះឡើងស្លូត ។

ឈុនលី ៖ ចុះដូចអ៊ំមេកង់ចឹងហូបដូចគេឬក៏ខុសគេ?

ធី ៖ អត់ទេ ហូបដូចគេ ។

ឈុនលី ៖ លើកដីដូចគេដែរអត់?

ធី ៖ បាទ បីម៉ែត្រណាស ។

ឈុនលី ៖ បីម៉ែត្រដូចគេដែរ?

ធី ៖ បាទ!

ឈុនលី ៖ ហើយហូបបាយជាមួយអីគេ?

ធី ៖ មិនទៀងទេ ជួនកាលក៏អំបិលលីងទៅ ជួនកាលនៅស្ងោប្រហុករកតែម្សៅស៊ុបហូបគ្មានផង គេហៅស្ងោរប្រហុកដាក់ម្ជូរស្លឹកខ្ទឹងស្លឹកអីនោះ ។

ឈុនលី ៖ ហើយពេលនោះឆ្ងាញ់ទេអ៊ំ?

ធី ៖ ឆ្ងាញ់ ។

ឈុនលី ៖ ហើយមានតែទឹកប្រហុកចឹងទេ អត់មានស្លម្ជូរស្លអីទេ?

ធី ៖ អត់មានទេសម្លម្ជូរក៏មានតែស្ងោព្រលិត ស្ងោត្រកួនម្សៅស៊ុបក៏មិនមានដែរមានតែអំបិល និងម្ជូរតែអារឿងម្សៅស៊ុបហ្នឹងមិនដែលស្គាល់ជាតិទេ ។

ឈុនលី ៖ ចឹងមានតែប្រៃៗហ្នឹង?

ធី ៖ បាទ!

ឈុនលី ៖ ចុះមានទឹកហូបទេ?

ធី ៖ ហួស! នៅត្រពាំងថ្មខ្សត់មែនទែននាងដាច់ទឹក បើនិយាយទៅអាទឹកផ្ងូតក៏មិនមានទឹកហូបក៏មិនមាន ។

ឈុនលី ៖ អត់ទឹកសោះ?

ធី ៖ បាទ!អត់មានទឹក ។

ឈុនលី ៖ គេមានវាល់ចែកគ្នាទេ?

ធី ៖ អត់ទេ ជាពិសេសបងប្អូនមកពីភ្នំពេញគាត់អត់ដែលធ្វើអីដល់មកធ្វើការហាលក្ដៅចឹងដូចជាវាហាក់ អត់មានទឹកចឹងទៅក្រវីតែក្បាលទៅអត់រួចស្លាប់បណ្ដើរៗ ។

ឈុនលី ៖ ខ្សោះទឹកអត់មានទឹកហូបម៉ង?

ធី ៖ មិនមានគេមិនឲ្យហូបតែម្ដង ។

ឈុនលី ៖ មានខ្លះដែរតើហ្អី គេចែកគ្នាដែរតើហ្អី?

ធី ៖ មានសំរាប់តែយើងហូប មាន ។

ឈុនលី ៖ មានប៉ុណ្ណាទៅ?

ធី ៖ ទឹកហូបម៉ាល្មមអត់ឲ្យសល់ទេម្នាក់ប្រហែលជា ចុះធ្វើការវាស់ៗល្ងាចហាលក្ដៅនោះដូចថាបីលីត្រទៅចុះ ។

ឈុនលី ៖ បីលីត្រច្រើនណាស់!

ធី ៖ អត់គ្រប់ទេ ។

ឈុនលី ៖ ម្នាក់?

ធី ៖ បាទ!ហូបអត់គ្រប់ទេក្ដៅណាស់ ។

ឈុនលី ៖ ចុះអ្នកខ្លះគេថាវាល់ស្លាបព្រា?

ធី ៖ បបរ?

ឈុនលី ៖ អត់ទេអ្នកខ្លះគេនិយាយថាទឹកហ្នឹងចែកគ្នាគេឲ្យម៉ាបំពង់ឬស្សីហ្នឹងយកមកចែកគ្នា ។

ធី ៖ ខ្ញុំនេះបើដាច់ទឹកមុជអីមាន ចុះបើទឹកនៅឆ្ងាយបីបួនគីឡូអាណាដើរទៅទំរាំបានទៅដល់កន្លែងទឹកនោះ ។

ឈុនលី ៖ ចុះទឹកហូបទៅយកខ្លួនឯងឬគេដឹកឲ្យ?

ធី ៖ ទឹកស៊ីទែនគេដឹកយកមកឲ្យ ។

ឈុនលី ៖ ដូចអ៊ីមេកងចឹងគេចែកឲ្យច្រើន?

ធី ៖ ដូចតែគ្នា យកមកដាក់រួមតែមួយ ។

ឈុនលី ៖ ម្នាក់បីលីត្រ?

ធី ៖ បាទ!យើងហូបក្នុងម៉ាថ្ងៃ ។

ឈុនលី ៖ ច្រើន បីលីត្រច្រើនណាស់អ៊ឹ?

ធី ៖ ហូស!មិនគ្រប់ទៀតបែកញើសវាស់ល្ងាចហើយហូបវាស់ល្ងាចមិនដឹងទឹកដឹកមកពីណាពីណីចេះតែហូបទៅ ។

ឈុនលី ៖ អ៊ីចឹងប៉ុន្មានថ្ងៃបានមុជទឹកទៅ?

ធី ៖ ជួនកាលទៅក៏ យ៉ាងយូរម៉ោយប់អីខ្ញុំ ។

ឈុនលី ៖ អ៊ីចឹងមុជរាល់ថ្ងៃហ្នឹង?

ធី ៖ យ៉ាងយូរដាច់ម៉ោយប់អានេះថាយើងអ្នកល្អែងចុះគ្នាអ្នករកកន្លែងទឹកនោះមិនឃើញ...

ឈុនលី ៖ ចុះអ៊ឹអត់ដែលដាច់ទឹកម៉ាអាទិត្យទេ?

ធី ៖ អត់ទេ ។

ឈុនលី ៖ ទឹកហ្នឹងទឹកប្រឡាយ?

ធី ៖ ទឹកបឹង ។

ឈុនលី ៖ អត់សូវមានអ្នកទៅមុជទេ?

ធី ៖ អត់ទេ ។

ឈុនលី ៖ អ៊ីចឹងអ៊ីល្អែងជាងគេហើយដែលទៅហ្នឹង?

ធី ៖ បាទ!ដូរគ្នាជាមួយ...ធម្មតាទៅនោះគេមានប្រធានកងតូចកងធំ បន្ទាប់ពីកងធំមកមានកងតូចសាមសិននាក់ ។

ឈុនលី ៖ ហើយអ៊ឹកាន់កងហ្នឹងកងអី?

ធី ៖ កងចល័តយើងហ្នឹង ។

ឈុនលី ៖ កងធំហ្នឹងប៉ុន្មាននាក់?

ធី ៖ ១០០នាក់ ។

ឈុនលី ៖ អ៊ីចឹងអ៊ឹកាន់កងធំ?

ធី ៖ បាទ!ប្រធានកងធំ ។

ឈុនលី ៖ អត់មានលក្ខណៈអីពិសេសជាងគេទេដូចអ៊ីប្រធានកងចឹង?

ធី ៖ អត់ទេ អានោះធ្វើទៅតាមបទបញ្ជាគេ គេដឹកនាំយើងទៅធ្វើ ។ ឧទាហរណ៍ថានៅភូមិនេះកំពុងដែរដេកស្រួលៗ យប់ម៉ោងដប់ម៉ាជណ្តប់ខែអស្សុច កក្តិកនេះរងារណាស់គេដាស់ទៅទាំងយប់ ខោអាវ ចប បង្គីទៅម៉ាំផ្លែដាក់សាក់ការដូ ។ បើនិយាយពីប្រវត្តិខ្ញុំនោះពីរថ្ងៃមិនចប់ផង ។

ឈុនលី ៖ អឹអាចរៀបរាប់ខ្លះៗបានទេ?

ធី ៖ វែងឆ្ងាយណាស់ ។

ឈុនលី ៖ ខ្ញុំចង់ដឹងការងារខ្លាំងដែលនៅត្រពាំងថ្មនេះណាសតាំងពីការហូបចុកយ៉ាងម៉េចៗ ការស្លាប់មនុស្សអីចឹងអឹអាចរៀបរាប់បានទេ?

ធី ៖ អារឿងស្លាប់ វាប្រើឲ្យយើងស្លាប់តែម្តង ប្រើបន្តត់ទឹកប្រើមិនឲ្យទឹកមុជបានន័យថាប្រើសំលាប់ ។

ឈុនលី ៖ ចុះមេរបស់អឹផ្ទាល់គឺ តាវ៉ាល់?

ធី ៖ បាទ!

ឈុនលី ៖ ចុះមានអ្នកណាទៀតដែលឋានៈដូចអឹ?

ធី ៖ ហួស!មានពីលើខ្ញុំ គេឥឡូវវរៈសេនាធំ មានប្រធានកងធំ មានវរៈសេនាធំ ។

ឈុនលី ៖ ឈ្មោះអីទៅ?

ធី ៖ ឈ្មោះដែរ ស្លាប់បាត់ហើយនៅភូមិនេះឯង ឈ្មោះស្រេះ ។

ឈុនលី ៖ តាស្រេះហ្នឹងមេវរៈសេនាធ្ន?

ធី ៖ បាទ!

ឈុនលី ៖ តែក្រោមតាវ៉ាល់?

ធី ៖ បាទ!ដាក់នេះមួយ តារ៉ុត ។

ឈុនលី ៖ តារ៉ុត?

ធី ៖ បាទ!នៅភូមិនេះឯងនៅដូនប្រែងនេះ ។

ឈុនលី ៖ ហួស!នៅដូនប្រែងរ៉ុតហ្នឹងហួស?

ធី ៖ បាទ!

ឈុនលី ៖ សព្វថ្ងៃហ្នឹងគាត់នៅហ្នឹង?

ធី ៖ ស្លាប់ហើយ ស្លាប់តាំងពីសម័យនិរតីចូលមក ។

ឈុនលី ៖ ប្រធានវរៈ?

ធី ៖ បាទ!

ឈុនលី ៖ វរៈសេនាធំ?

ធី ៖ បាទ!

ឈុនលី ៖ ចុះអ្នកដែលឋានៈដូចអឹមមេកងៗ?

ធី ៖ បែកបាក់គ្នាអស់ ក្មេចអស់ហើយបែកគ្នា ។

ឈុនលី ៖ តែពេលធ្វើការចឹងបើមានអ្នកឈឺអីមានទៅប្រាប់មេគេអីទេ?

ធី ៖ ឃើញឈឺចឹងឲ្យទៅពេទ្យ ពេទ្យអន្តភាពយើង ។

ឈុនលី ៖ នៅឯណាទៅអាហ្នឹង?

ធី ៖ នៅជាមួយគ្នាដែរ ពេទ្យក៏គេដេកជាមួយគ្នាតែគ្រាន់តែថាគេគ្រាន់ជាងបន្តិច ប្រដាប់ប្រដាគេប្រើប្រាស់មានអង្រឹងមានអីបិទបាំង ។

ឈុនលី ៖ អីចឹងរយៈពេលបានហើយទំនប់ត្រពាំងថ្ម?

ធី ៖ រយៈពេលម៉ាខែកន្លះ ។

ឈុនលី ៖ ម៉ាខែកន្លះហើយ?

ធី ៖ បាទ!

ឈុនលី ៖ ម៉ាខែកន្លះហើយៗទៅណាទៀត?

ធី ៖ ខ្ញុំចាប់ដៃឲ្យ តាវ៉ាល់ ការឲ្យនៅទំនប់នៅស្ពានរាបហ្នឹង ។

ឈុនលី ៖ ស្នើរដែរអត់?

ធី ៖ ស្នើរ ។

ឈុនលី ៖ ចុះខាងស្រីគាត់ធ្វើអីគេ?

ធី ៖ ខាងស្រីគេប្រធានកងដែរ ។

ឈុនលី ៖ ពេលហើយទំនប់ហ្នឹង?

ធី ៖ បាទ!

ឈុនលី ៖ ឆ្នាំណា ៧៧?

ធី ៖ ៧៧ កន្លះ ។

ឈុនលី ៖ ស្នើរ តាវ៉ាល់តែម្តង?

ធី ៖ បាទ!ស្នើរប្រធានកងខាងស្រីគេ តាវ៉ាល់គាត់មានដឹងអី ។

ឈុនលី ៖ ចុះស្នើរហ្នឹងត្រឹមណា?

ធី ៖ ស្នើរអាចប់ទំនប់ ។

ឈុនលី ៖ អត់ទេនិយាយថាអីស្នើរ ស្នើរអ្នកណាដើម្បីការហ្នឹង?

ធី ៖ ហួស!ប្រពន្ធខ្លួនឯងនោះ?

ឈុនលី ៖ ចាស! ទៅសុំមេ អ្នកណា?

ធី ៖ ទៅសុំមេគេខាងស្រីឈ្មោះ រី ។

ឈុនលី ៖ គាត់ហ្នឹងប្រធានកងឬអ្នកធ្វើការនៅក្នុងកង?

ធី ៖ ប្រធានកងតូច ។

ឈុនលី ៖ ប្រធានកងតូច សាមសិបនាក់?

ធី ៖ បាទ!

ឈុនលី ៖ ហើយអ៊ំទៅសុំហ្នឹងសុំត្រឹមណា ធម្មតាយើងមិនត្រូវសុំអនុញ្ញាតិពីមេ?

ធី ៖ បាទ!

ឈុនលី ៖ ស្នើរដល់មេ?

ធី ៖ មេហ្នឹងស្លាប់បាត់ហើយ ។

ឈុនលី ៖ មេឈ្មោះអី?

ធី ៖ ឈ្មោះវ័ន្ត ។

ឈុនលី ៖ ឈ្មោះវ័ន្ត មេហ្នឹងមេរបស់ខាងស្រីទេហ្អី?

ធី ៖ មេខាងស្រី ប្រធានខាងស្រីណាស?

ឈុនលី ៖ ចាស!ហើយ តាវ៉ាល់អត់ដឹងតែ?

ធី ៖ ដឹង ដល់ស្នើរបានគេព្រមព្រៀងទៅបានយើងបានឈ្មោះដល់ តាវ៉ាល់ ។

ឈុនលី ៖ គាត់អ្នកសំរេច?

ធី ៖ គាត់សំរេច ។

ឈុនលី ៖ ហើយការនៅទំនប់នោះទៅ?

ធី ៖ បាទ!

ឈុនលី ៖ ហើយយើងការហើយចឹងទៅណា?

ធី ៖ ការហើយឲ្យមកនៅអគ្គភាពយើងនៅអារក្សបាក់ក អត់មានឲ្យមកនៅជាមួយម៉ែឪទេ ឲ្យមកនៅអគ្គភាពមានប្រធានដឹកនាំផ្សេងទៀត ។

ឈុនលី ៖ អ្នកណាគេដឹកនាំ?

ធី ៖ ឈ្មោះតាលាំៗ ។

ឈុនលី ៖ តាលំ?

ធី ៖ បាទ!

ឈុនលី ៖ នៅអារក្សបាក់ករ?

ធី ៖ បាទ!

ឈុនលី ៖ អាហ្នឹងជាអី ជាភូមិ?

ធី ៖ បាទ!

ឈុនលី ៖ នៅហ្នឹងធ្វើអីគេ?

ធី ៖ ឲ្យមកនៅធ្វើស្រែនៅវាលកំបោរ ។

ឈុនលី ៖ អីចឹងអឹឈប់ធ្វើមេកងទៅធ្វើនៅកូនខ្វែងទៀតហើយ?

ធី ៖ បាទ!

ឈុនលី ៖ ចឹងអ៊ឹអត់បានទៅកូនខ្វែងអីទេ?

ធី ៖ អត់ទេចប់ហើយ ។

ឈុនលី ៖ ធ្វើតែទំនប់ម៉ាខែកន្លះហ្នឹងហើយដែរ?

ធី ៖ បាទ!

ឈុនលី ៖ ហើយរួចរាល់ម៉ង?

ធី ៖ បាទ!

ឈុនលី ៖ លឿនម្លេះម៉ាខែកន្លះ?

ធី ៖ ចុះកំលាំងពីរពាន់នាក់ហើយ ។

ឈុនលី ៖ ត្រពាំងថ្មណាស?

ធី ៖ បាទ!

ឈុនលី ៖ មិនមែនបីបួនខែទេ?

ធី ៖ អត់ទេ ។

ឈុនលី ៖ ចុះពេលហើយអត់មានអ្នកណាគេមើលថែទេ មកវិញទាំងអស់គ្នាប្តុក៏ដកមកខ្លះ?

ធី ៖ អានោះដូចថាចប់តែទំនប់ហើយការ ខ្ញុំការហើយបានប្រហែលពីរខែពួកនិរតីចូលមក ។

ឈុនលី ៖ អាហ្នឹងនៅអារក្សបាក់ករ?

ធី ៖ នៅអារក្សបាក់ករ ដល់ចប់ទំនប់បានប្រពន្ធមកនៅអារក្សបាក់ករ ។

ឈុនលី ៖ ចុះដល់ពេលនិរតីមកយ៉ាងម៉េច?

ធី ៖ ទេ ពួកនោះមកស្រួលវិញ ។

ឈុនលី ៖ ម៉េចបានស្រួល?

ធី ៖ គេឲ្យយើងហូបមានជាតិស្ករមានអី ហើយគេប្រើយើងធម្មតា ។

ឈុនលី ៖ ពេលនោះតាវ៉ាល់ស្លាប់ហើយឬនៅ?

ធី ៖ ពេលនោះខ្ញុំកមកមិនដឹងគាត់ស្លាប់ឬរស់ទេ ។

ឈុនលី ៖ ចុះអ្នកនិរតីមកហ្នឹងធ្វើអីខ្លះទៅឋានៈគេ?

ធី ៖ ស្គាល់តែម្នាក់ទេប្រធានខ្ញុំ ។

ឈុនលី ៖ ប្រធានហ្នឹងគេហៅប្រធានអី ប្រធានកង ប្រធានភូមិ ប្រធានក្រុម?

ធី ៖ ប្រធានភូមិ ។

ឈុនលី ៖ អ្នកមកហ្នឹងប្រធានភូមិ?

ធី ៖ បាទ!

ឈុនលី ៖ ឈ្មោះអី ស្រីឬប្រុសអ៊ឹ?

ធី ៖ ប្រុស ឈ្មោះសែក តាសែក ។

ឈុនលី ៖ ឈ្មោះសែក?

ធី ៖ បាទ!

ឈុនលី ៖ ប្រុស?

ធី ៖ បាទ!

ឈុនលី ៖ គាត់ស្រួលយ៉ាងម៉េចទៅ?

ធី ៖ ស្រួលដូចថាគាត់ដឹកនាំល្អពាក្យសំដីក៏ល្អ ។

ឈុនលី ៖ ចុះពេលហ្នឹងអ៊ំធ្លាប់ឮឈ្មោះយាយថែមដែរអត់?

ធី ៖ ឮ ។

ឈុនលី ៖ ចុះពេលទៅនៅអារក្សបាក់កហ្នឹងអ៊ំធ្វើមេកងទៀតអត់?

ធី ៖ អត់ទេ ។

ឈុនលី ៖ គេឲ្យលើកដីវិញ?

ធី ៖ បាទ! លើកដីធ្វើស្រែ ។

ឈុនលី ៖ អារក្សបាក់ករជាភូមិឬជាអី?

ធី ៖ ពីដើមមិញវាលហើយ ។

ឈុនលី ៖ ហើយគេដាក់យ៉ាងម៉េចឲ្យយើងនៅចោះ ។

ធី ៖ អានោះគេដាក់ថាអន្តភាព តានោះកន្វែងគាត់កាចណាស់ យកយើងទៅលត់ដំតែម្តង ។

ឈុនលី ៖ ហេតុអីបានលត់ដំ យើងខុសអី?

ធី ៖ មិនដឹងថាយ៉ាងណា យកទៅភ្ជួរស្រែនៅវាលកំបោរហើយកង់ស្នៀប៉ុនណាណីភ្ជួរនង្គ័លគោ ហើយបើអ្នកណាភ្ជួរបាក់នង្គ័លគេដៀលយើងសុទ្ធតែយើងកូនអ្នកមាន គ្រូ សាស្ត្រាចារ្យ ឯណា ជួបការលំបាកច្រើន ។

ឈុនលី ៖ ចុះប្រពន្ធអ៊ំគាត់ធ្វើមេកងដែរ?

ធី ៖ បាទ!

ឈុនលី ៖ ដល់ពេលមកវិញណាសមកនៅអារក្សបាក់ករ?

ធី ៖ ឈប់ហើយ ។

ឈុនលី ៖ ការហើយគេឈប់ឲ្យធ្វើមេកងហើយ?

ធី ៖ បែកគ្នារួច គេបំបែកពីត្រពាំងថ្មមកនៅអន្លក់ភាពតាលាំ ។

ឈុនលី ៖ ធ្វើស្រែ?

ធី ៖ បាទ!

ឈុនលី ៖ មានប្រជាជនរស់នៅហ្នឹងច្រើនដែរអត់?

ធី ៖ ច្រើន ។

ឈុនលី ៖ ភាគច្រើនគេធ្វើអីនៅហ្នឹង?

ធី ៖ ធ្វើចំការផងស្រែផង ។

ឈុនលី ៖ ចំការដាំអីគេ?

ធី ៖ ដាំដំឡូង ដាំអំពៅ ។

ឈុនលី ៖ ដាំហើយយកទៅណា.?

ធី ៖ អត់បានយកទៅណាទេធ្វើបានក៏ដោះស្រាយហូបតិចៗប៉ុន្តែអានោះក៏សល់ ។

ឈុនលី ៖ បានហូបច្រើនដែរអត់ចឹង?

ធី ៖ អត់ទេ ។

ឈុនលី ៖ ដល់ពេលធ្វើការក្នុងភូមិហ្នឹងហូបអីគេ?

ធី ៖ ហូបបបរ ។

ឈុនលី ៖ ច្រើនទេ?

ធី ៖ អត់ច្រើនទេ ម៉ាកាតូ ។

ឈុនលី ៖ ច្រើនៗណាស់ចឹង?

ធី ៖ បាទ! បើម្នាក់ឯងនោះម៉ាកាតូនោះ ។

ឈុនលី ៖ សុទ្ធតែទឹកហើយមើលទៅ?

ធី ៖ ទឹកកន្ទះកាតូ ។

ឈុនលី ៖ ចុះពេលណាយាយថែមចូលមក យាយថែមចូលមកជាមួយ គាសែកដែរ?

ធី ៖ យាយថែម ចូលមកផ្សេងទេ ។

ឈុនលី ៖ ផ្សេងយ៉ាងម៉េចទៅអ៊ី?

ធី ៖ យាយថែម ខ្ញុំមិនដែលស្គាល់គាត់ច្បាស់ទេខ្ញុំមិនដែលឃើញមុខគាត់ច្បាស់ផង ។

ឈុនលី ៖ អត់ដែលឃើញមុខយាយថែមទេ?

ធី ៖ អត់ទេ សម័យនោះមានបានដើររកគ្នាឯណា ។

ឈុនលី ៖ តែធ្លាប់ឮឈ្មោះ?

ធី ៖ បាទ!ធ្លាប់ឮឈ្មោះ

ឈុនលី ៖ ចុះអ៊ីមានដឹងយាយថែម គាត់ឋានៈអីគេ?

ធី ៖ ឋានៈយាយថែម បើនិយាយឲ្យដល់ទៅមនុស្សគាត់មេបណ្ដោយ ។

ឈុនលី ៖ មេអីគេ?

ធី ៖ មេពួកខ្មែរក្រហម ។

ឈុនលី ៖ តែឋានៈអីគេ គណៈស្រុក គណៈឃុំឬយ៉ាងម៉េចអ៊ី?

ធី ៖ គាត់ហ្នឹងមើលទៅប្រហែលគណៈស្រុក ចុះគាត់នៅខាងស្រុកព្រះនេត្រព្រះ ។

ឈុនលី ៖ គណៈស្រុកតែគាត់មកជាមួយអ្នកនិរតីដែរអត់?

ធី ៖ ខ្ញុំចាំមិនច្បាស់ទេ ទេយាយថែមមកមុន យាយថែមខ្ញុំចាំកាលឆ្នាំ៧៦ ។

ឈុនលី ៖ ទេអ៊ីយាយថែមគាត់មិនមែនមក៧៦ទេហ្អី?

ធី ៖ ទាល់តែសួរម្នាក់នោះបានច្បាស់ជាងខ្ញុំ ។

ឈុនលី ៖ គាត់ធ្វើអីគេ?

ធី ៖ គាត់បើនិយាយឲ្យដល់ទៅគាត់កងផង អាជីវកម្មផង អាជីវកម្មទៅរកត្រីឲ្យអង្គភាព ។

ឈុនលី ៖ អ៊ីមេកងអត់មានការងារច្រើនដូចគេទេ?

ធី ៖ ទេ ។

ឈុនលី ៖ ធ្វើការដូចគេដូចឯងដែរ?

ធី ៖ បាទ!វែកដីដែរបើមិនចុះស្មានតែគេគេសុខចិត្តហ្អីនាង គេប្រណែនយើងសូម្បីតែមេដល់ណាក៏ដោយ ។

ឈុនលី ៖ ដូចគាត់ប្រហែលអត់ធ្វើការច្រើនទេហ្អី? ថាន់ៈដូចគាត់?

ធី ៖ បាទ!

ឈុនលី ៖ ពេលទៅធ្វើការនៅត្រពាំងថ្មជួបគាត់ដែរ?

ធី ៖ ជួប ៗ

ឈុនលី ៖ គាត់ធ្វើអីគេ គាត់រែកដីដែរអត់?

ធី ៖ កាលនោះគាត់នៅរកត្រីឯក្រោម បើនិយាយទៅគាត់បានទ្រឹស្តីស្អាតដឹកនាំស្អាត ហើយកំលាំងមិនដល់ខ្ញុំទេខ្ញុំធ្វើការដូចកូនកង ៗ

ឈុនលី ៖ ហើយពេលមកនៅចឹងធ្វើស្រែហើយទៅណាទៀតអត់ ធ្វើចំការធ្វើអីចឹង?

ធី ៖ ទៅនៅគោកពន្របានប្រហែលម៉ាឆ្នាំក៏វៀតណាមចូលមករំដោះ ៗ

ឈុនលី ៖ គោកពន្រ?

ធី ៖ បាទ!

ឈុនលី ៖ ម៉េចបានជម្លៀសទៅនៅគោកពន្រវិញ?

ធី ៖ អស អារក្សបាក់ករ នៅអារក្សបាក់កនេះធ្វើស្រែ ៗ

ឈុនលី ៖ ប្រហែលម៉ាឆ្នាំ?

ធី ៖ បាទ!

ឈុនលី ៖ ពេលវៀតណាមចូលអ៊ំទៅណា?

ធី ៖ មកនៅដូនប្រែងនេះ ៗ

ឈុនលី ៖ ពេលវៀតណាមចូលសភាពការណ៍នៅនេះម៉េចដែរ?

ធី ៖ សភាពការណ៍មានភ្ញាក់ផ្អើលដែរនាងត្រង់នោះបើពាក្យឃោសនាសុទ្ធតែអាសម្បត្តិអាអីឃើញយើងនៅក្នុងភូមិអីសុទ្ធតែអាករចោល ហើយក៏នាំគ្នាគេចពីភូមិទៅមង្គលបុរី ៗ

ឈុនលី ៖ ចឹងពេលវៀតណាមចូលគេចទៅមង្គលបុរី?

ធី ៖ បាទ! ទៅមង្គលបូរី ទៅនោះក៏មិនយូរដែរមើលតែសភាពការណ៍ស្រួលនាំគ្នាចូលមកក្នុងភូមិ

ឈុនលី ៖ ភូមិណា?

ធី ៖ ដូនប្រែង ៗ

ឈុនលី ៖ ចុះបន្ទាប់ពីមកដល់ភូមិហើយយ៉ាងម៉េចទៀត? ពេលនោះមានកូនចៅប្អូនៅ?

ធី ៖ កាលជំនាន់នោះ?

ឈុនលី ៖ ចាស!

ធី ៖ មានកូនមួយ ។

ឈុនលី ៖ ស្រីឬប្រុស?

ធី ៖ ស្រី ។

ឈុនលី ៖ កើតឆ្នាំណាកូន?

ធី ៖ ឆ្នាំមមី ។

ឈុនលី ៖ កើតមួយពាន់ប្រាំបួនរយប៉ុន្មាន?

ធី ៖ ៧៩ ឆ្នាំឃ្លួនចូលមក ។

ឈុនលី ៖ ចុះពេលមកនៅក្នុងភូមិហើយម៉េចទៀតអ៊ីលែងទៅណាទៀតហើយ?

ធី ៖ អត់ទេ ទៅនៅខាងប្រពន្ធ ។

ឈុនលី ៖ ហ្នឹងហើយ នៅធ្វើអីទៀត?

ធី ៖ ធ្វើស្រែ ។

ឈុនលី ៖ ពេលហ្នឹងគេឈប់មានសហករណ៍អីហើយ?

ធី ៖ បាទ!

ឈុនលី ៖ ធ្វើស្រែហ្នឹងធ្វើឯកជនទេតើហ្អី?

ធី ៖ បាទ!ឯកជន ។

ឈុនលី ៖ ចុះក្រោយមកគេធ្វើអីទៀត គេមានរើសទាហានរើសអីទៀតទេ?

ធី ៖ រើស ។

ឈុនលី ៖ អ៊ីចូលដែរ?

ធី ៖ អត់ ខ្ញុំចូលខាងវីរៈសេនាជនផុតពីទាហានទៅវីរៈសេនាជនមួយឆ្នាំ ។

ឈុនលី ៖ ចេញពីទាហានយ៉ាងម៉េចអ៊ីធ្លាប់ធ្វើទាហានដែរ?

ធី ៖ អត់ទេ ទៅវីរៈសេនាជន ។

ឈុនលី ៖ វីរៈសេនាជនបានន័យថាម៉េច?

ធី ៖ និយាយទៅដូចតែទាហានយកទៅនៅម៉ាឡៃ ណាំសាប ។

ឈុនលី ៖ ទៅនៅម៉ាឡៃ?

ធី ៖ បាទ!

ឈុនលី ៖ ឆ្នាំណាដែរ?

ធី ៖ កាលនោះឆ្នាំ៨៦ ។

ឈុនលី ៖ យូរម្លេះមិនមែន៨១ ៨២ទេ?

ធី ៖ ទេ៨៦ ។

ឈុនលី ៖ ការងារយ៉ាងម៉េចវីរៈសេនាជន?

ធី ៖ វីរៈសេនាជនកងទ័ព ។

ឈុនលី ៖ ចុះម៉េចគេអត់ហៅទាហាន?

ធី ៖ វិរៈសេនាជនការពារព្រំដែន លោក ហ៊ុន សែនអ្នកដឹកនាំឲ្យ ។

ឈុនលី ៖ ចុះក្រោមការដឹកនាំរបស់អ្នកណាទៀតមេធំ? សុខ ភាពហ្អីនៅម៉ាឡៃ?

ធី ៖ មិនដឹងលោកណាទេ ។

ឈុនលី ៖ ហើយបានច្បាំងនឹងគេទេនៅព្រំដែន?

ធី ៖ អត់ទេ ។

ឈុនលី ៖ នៅម្តុំណា?

ធី ៖ ខ្ញុំនៅម៉ាឡៃតូច ។

ឈុនលី ៖ ម៉ាឡៃតូចនៅក្នុងឃុំអីគេ?

ធី ៖ អត់ស្គាល់ទេនៅក្នុងដុបក្នុងព្រៃអត់ទាន់មានឃុំអីទេ ។

ឈុនលី ៖ ៨៦មានហើយហ្អី?

ធី ៖ អត់ទេ អត់មានទេ ។

ឈុនលី ៖ ចុះពេលនោះខ្មែរក្រហមជម្លៀសពីខេត្តទៅមិនចូលទៅនៅម៉ាឡៃហ្នឹងខ្ទង់៧៩ ៨០ ។ ៨៥គេនាំគ្នាជម្លៀសចេញពីជំរុំមកវិញហើយហ្នឹង ។

ធី ៖ កៅទេតើនាង ៩៣ ៩៤ ប្អូនថ្លៃខ្ញុំទើបតែមកពីជំរុំ ខ្ញុំទៅកាលនោះ១៩៨៦ខ្ញុំកត់នៅក្រោមផ្ទះខ្ញុំ ។

ឈុនលី ៖ ៨៦?

ធី ៖ បាទ!អត់មានមនុស្សទេ ។

ឈុនលី ៖ មកពីអីនៅក្នុងព្រៃទេដឹង?

ធី ៖ អត់ទេទៅនៅជុំទាហានបណ្តោយ ។

ឈុនលី ៖ តែប្រជាជនផ្សេងទេហ្អី?

ធី ៖ អត់មានប្រជាជនផង ប្រជាជននៅត្រឹមបាវិល នៅត្រង់បួរ ។

ឈុនលី ៖ អីចឹងបានន័យថាប្រជាជននាំគ្នាទៅនៅព្រំដែនថៃហើយបានអត់មានមនុស្សនោះ?

ធី ៖ ត្រូវហើយកាលនោះបែបចូលទៅថៃ អាខ្លះនៅខ្មែរអាខ្លះចូលទៅថៃសម័យកាលនោះ...

ឈុនលី ៖ ទាហានព្រំដែនមានប្រហែលប៉ុន្មាននាក់ទៅ?

ធី ៖ មិនដឹងដែរមកម៉ាវរៈសេនាធំនៅណាំសាប ។

ឈុនលី ៖ ណាំសាប?

ធី ៖ បាទ! នៅវរៈសេនាធំ ។

ឈុនលី ៖ ចុះមិនមែននៅកន្លែងកូនដីរ៉េទេ?

ធី ៖ កូនដីរ៉េយើងផ្លូវទៅប៉ោយប៉ែតនេះ?

ឈុនលី ៖ ចាស! នៅកន្លែងនោះមានកងពលមួយ ។

ធី ៖ បាទ! អានោះផ្សេងអានោះខាងទាហានផ្សេង ។

ឈុនលី ៖ មកពីយើងនៅខាងព្រំដែនអត់ចូលកងពលហ្នឹងគេហ្អី?

ធី ៖ យើងនៅអីនោះមានដឹងអីណានាង ខាងព្រំដែនផ្សេង ខាងនេះផ្សេង ខាងនេះនៅក្រោយ ។ ខ្ញុំទៅកាលនោះមិនណាស់ ។

ឈុនលី ៖ មិនច្រើន?

ធី ៖ បាទ!

ឈុនលី ៖ ហើយកាលណាបានឈប់មកវិញអីនោះ?

ធី ៖ ឆ្នាំ១៩៨៧ខ្ញុំមកវិញ ។

ឈុនលី ៖ មកវិញធ្វើអី ឈប់ធ្វើវរៈសេនាជនទៀតហើយ?

ធី ៖ ឈប់ដល់ឈប់ទៅគេដល់សម័យចាប់ទាហានទៀតហើយ ។

ឈុនលី ៖ គេចាប់ទាហានទៀតម៉េចអឹងអត់ចូល?

ធី ៖ ដល់ឈ្មោះខ្ញុំបានទៅវរៈសេនាជនទៅផុតម៉ាគ្រា ។

ឈុនលី ៖ ហើយចឹងមានទៅណាទៀតអត់?

ធី ៖ អត់ទេចប់ ។

ឈុនលី ៖ នៅហ្នឹងរហូត?

ធី ៖ បាទ! ធ្វើស្រែ ។

ឈុនលី ៖ អឹងសប្បាយនិយាយរឿងរ៉ាវប្រាប់កូនដែររឿងប្រវត្តិខ្លួនឯងរឿងខ្មែរក្រហមរឿងលើកទំនប់យ៉ាងម៉េចៗ?

ធី ៖ ប្រាប់ដែរនាង ។

ឈុនលី ៖ គេជឿដែរ?

ធី ៖ ទេ ជឿឪនិយាយប្រាប់ហើយជឿព្រោះខ្ញុំឆ្លងកាត់ការលំបាកចប់សម័យកាលនោះ ។

ឈុនលី ៖ ជឿម៉េងហ្នឹ?

ធី ៖ បាទ!ថាកូនឯងសំណាងហើយសម័យនេះកូនឯងបានស៊ីឆ្អាញ់ដេកស្រួល ដេកទល់ៗភ្លឺ បើកាលសម័យពុកហូបតែបបរហើយកំពុងតែដេកស្រួលអាយុ១៧ ១៨កំពុងតែពេញ ហូបពេញដេកហៅទៅទាំងយប់នាងអីយ!

ឈុនលី ៖ ចុះកូនចៅស្តាប់ពុចឹងយ៉ាងម៉េចទៅ?

ធី ៖ ពុវាទៅតែស្ងៀម ។

ឈុនលី ៖ ហើយអីសប្បាយចិត្តទេពេលកូនចៅជឿចឹង?

ធី ៖ សប្បាយ ។

ឈុនលី ៖ ចុះបើអត់ជឿវិញ?

ធី ៖ អត់ជឿអត់សប្បាយ អានេះវាមិនជឿយើង ។ ជឿរបូតសព្វទាល់តែសព្វថ្ងៃអីរស់នៅ មានប្រវត្តិតស៊ូធ្វើឲ្យឃើញជាក់ស្តែងចឹងទៅកូនរឹតតែស្រឡាញ់ ។

ឈុនលី ៖ អីដែលដឹងរឿងគេកាត់ទោសមេដឹកនាំខ្មែរក្រហមទេ?

ធី ៖ អត់ទេនាង ។

ឈុនលី ៖ អត់ដឹងទេ?

ធី ៖ បាទ!

ឈុនលី ៖ សព្វថ្ងៃគេកំពុងតែមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមណាសអីដូច នួន ជា អៀង សារី អៀង ធិរិទ្ធ ខៀវ សំផន ឌុចអី អីដែលពុឈ្មោះពួកគាត់ទេ?

ធី ៖ ពុ ។

ឈុនលី ៖ ពុពេលណាទៅ?

ធី ៖ លោកខៀវ សំផនលោកអីធ្លាប់ពុតាំងពីសម័យ៧៥ ។

ឈុនលី ៖ ពុពេលណា?

ធី ៖ ពុថាគាត់ធ្វើក្បួនទ័ព តែអារឿងចរិតយ៉ាងណាក៏ខ្ញុំមិនដឹងដែរ ។

ឈុនលី ៖ ចុះកាលនោះស្គាល់ឈ្មោះតាហ៊ីងទេ?

ធី ៖ តាហ៊ីង ភ្លេច ។

ឈុនលី ៖ ចុះអីពេញចិត្តនឹងមានតុលាការកាត់ទោសខ្មែរក្រហមទេ?

ធី ៖ ពេញចិត្តណាស់ ។

ឈុនលី ៖ ចុះអ៊ីមានបាត់បង់បងប្អូនទេ?

ធី ៖ បាត់ ។

ឈុនលី ៖ បាត់ប៉ុន្មាននាក់ទៅ?

ធី ៖ ស្លាប់កាលសម័យនោះ?

ឈុនលី ៖ ចាស! បងប្អូនបង្កើតណាស?

ធី ៖ បាទ!យាយតា ជីដូនមួយខាងឪពុកខ្ញុំ ។

ឈុនលី ៖ ស្លាប់ដោយសារអី?

ធី ៖ ដូចថាគេយកទៅវ៉ៃចោលគេថាយើងជាប់ពូជអ្នកមាន ។

ឈុនលី ៖ ហើយអ៊ីដឹងទេកាលនោះ?

ធី ៖ ដឹង ។

ឈុនលី ៖ ហើយធ្វើម៉េចទៅ?

ធី ៖ ដឹងទៅក៏មិនអាចទៅជួយបានព្រោះយើងនៅឆ្ងាយគេបំបែកឲ្យយើងទៅភ្ជួរស្រែនៅវាល គាត់នៅនៅផ្សេងនៅភូមិ ។

ឈុនលី ៖ ម៉េចបានគេចោទថាខ្សែអ្នកមាន ពីដើមគាត់ធ្វើអី?

ធី ៖ គាត់អ្នកស្រែហ្នឹង គាត់កាន់តែសីលតាំងពីសម័យ៧៤ ៧៥ ។

ឈុនលី ៖ ទាំងយាយតាំងតាទាំឪពុកម្តាយ គាត់ចាស់ៗហ្អី?

ធី ៖ បាទ!គាត់ចាស់ គាត់យាយតាខ្ញុំនោះ ។

ឈុនលី ៖ ចុះម្តាយឪពុក?

ធី ៖ ម្តាយឪពុកខ្ញុំនៅ ។

ឈុនលី ៖ សព្វថ្ងៃនៅ?

ធី ៖ ស្លាប់អស់ហើយ ។

ឈុនលី ៖ ស្លាប់ពេលណា?

ធី ៖ ស្លាប់គាត់ឈឺ ។

ឈុនលី ៖ ក្នុងឆ្នាំណា ចិតជាងដែរអត់ ក្នុងសម័យខ្មែរក្រហមឬក៏ក្រោយ?

ធី ៖ ទេ ស្លាប់នៅសម័យនេះឯងពីរបីឆ្នាំ ។

ឈុនលី ៖ តែដល់ពេលជីដូនជីតាហ្នឹងស្លាប់នៅសម័យខ្មែរក្រហម?

ធី ៖ បាទ!

ឈុនលី ៖ ពេលនោះអ៊ំព្រងើយដែរ?

ធី ៖ ព្រ កាលនោះសម័យ៧៥ដែលគេចូលពួកខ្មែរក្រហមចូលរំដោះ ។

ឈុនលី ៖ អ៊ីចឹងអ៊ំមានអីចង់បន្ថែមទៀតទេ?

ធី ៖ ទេនាង!អស់ហើយ ។

ឈុនលី ៖ អ៊ីចឹងអគុណហើយអ៊ំ ។

«ចប់»